អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥

សេចក្តីប្រកាសព័ត៌មាន
ការកែសម្រួលកាលវិភាគសវនាការពីថ្ងៃទី ៣០ ខែ មីនា ដល់ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបដែលមានរហស្សនាម 2-TCW-923 តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ ដោយសារតែពេលវេលាខុសគ្នា អង្គជំនុំជម្រះនឹងធ្វើសវនាការចាប់ពីម៉ោង ៨.០០ ព្រឹករហូតដល់ម៉ោង ១០.០០ ព្រឹក សម្រាប់រយៈពេលបីថ្ងៃ គឺពីថ្ងៃទី ៣០-៣១ ខែ មីនា និងថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១៥ ហើយអង្គជំនុំជម្រះនឹងមិនធ្វើសវនាការបន្តទៀតទេនៅអំឡុងថ្ងៃទាំងនេះ។ សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនទទួលរង នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២-៣ ខែ មេសា ឆ្នាំ ២០១៥ ដោយចាប់ផ្តើមពីម៉ោង ៩.០០ ព្រឹកតទៅ។

សវនាការនឹងត្រូវផ្សព្វផ្សាយផ្ទាល់នៅលើគេហទំព័ររបស់ អ.វ.ត.ក www.eccc.gov.kh/en/live-stream

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org